# សាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូ

東京外国語大学 Tokyo University of Foreign Studies (T.U.F.S.)




សាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូ (TUFS) ផ្តល់បរិញ្ញាប័ត្រផ្នែកសិក្សា និងស្រាវជ្រាវភាសាចំនួន ២៦ គឺ អង់គ្លេស បារាំង អាល្លឺម៉ង់ អ៊ីតាលី អេស្ប៉ាញ៉ុល ព័រទុយហ្គាល់ រុស្ស៊ី ប៉ូឡូញ ឆែក ចិន កូរ៉េ ម៉ុងហ្គោលី ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពិន ថៃ លាវ វៀតណាម ខ្មែរ ភូមា អ៊ូរឌូ ហិនណ្ឌូ អារ៉ាប់ ពែរ្ស៊ីយ៉ា ទួរគី និង ជប៉ុន។

នៅសាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូមាននិស្សិតសរុបទាំងអស់ចំនួន ៤,៩៨០នាក់ ក្នុងនោះមាននិស្សិតបរទេសចំនួន ៦៧៥នាក់ ដែលមកពីប្រទេសជាង ៣០។ សាកលវិទ្យាល័យមានសាស្ត្រាចារ្យចំនួន ២២៣នាក់ និង បុគ្គលិក ១០៧នាក់។

## ប្រវត្តសាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូ

សាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូ កសាងឡើងនៅឆ្នាំ១៨៥៧ ជាមហាវិទ្យាល័យមួយដ៏ចំណាស់ជាងគេនៅក្នុងប្រទេសជប៉ុន ដែលសិក្សាស្រាវជ្រាវអំពីបរទេស។ សាកលវិទ្យាល័យនេះបានក្លាយជាស្ថាប័នផ្លូវការមួយរបស់រដ្ឋចាប់ពីឆ្នាំ១៨៩៩ដែលមានឈ្មោះថាមហាវិទ្យាល័យសិក្សាស្រាវជ្រាវឯកសារបរទេស ដែលស្ថិតនៅកណ្តាលតូក្យូ។ បច្ចុប្បន្ននេះសាកលវិទ្យាល័យ TUFS ជាសាកលវិទ្យាល័យថ្មីទើបតែសាងសង់ក្នុងឆ្នាំ២០០០ ដែលស្ថិតនៅ ហ្វូជឺ។

## បណ្ណាល័យ

បណ្ណាល័យនៅក្នុងសាកលវិទ្យាល័យTUFSមានសៀវភៅជាង ៦១៨,០០០ក្បាល ព្រមទាំងកាសែត និងទស្សនាវដ្តី ៧,០៤៣ ប្រភេទដែលបានបោះពុម្ពផ្សាយជាង១០០ភាសា។ ក្នុងនោះមានសៀវភៅជាភាសាខ្មែរចំនួន១,០៤០ ហើយមានសៀវភៅខ្លះបោះពុម្ពតាំងពីឆ្នាំ១៩៥០មកម្ល៉េះ។ ក្រៅពីនេះនៅមានសៀវភៅដែលបានសរសេរ ឬបោះពុម្ព តាំងពីសតវត្សទី ១៦មកម្ល៉េះ។

## ក្លឹបកីឡា

នៅក្នុងសាកលវិទ្យាល័យTUFS មានក្លឹបកីឡាច្រើនប្រភេទ ដូចជា បាល់ទាត់ បាល់ទះ បាល់បោះ អុំទូក ជាដើម។ ក្នុងក្លឹបនីមួយៗពុំមានចំនួនសមាជិកច្បាស់លាស់ទេ ពីព្រោះនិស្សិតខ្លះចូល និស្សិតខ្លះចាកចេញ ដោយពួកគេមិនមានពេលហាត់គ្រប់គ្រាន់។



# ■ ផ្នែកភាសាខ្មែរ ■

## ផ្នែកភាសាខ្មែរ

ក្រសួងអប់រំបានអនុញ្ញាតឲ្យសាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូ បង្កើតផ្នែកភាសាខ្មែរឡើង តាំងពីឆ្នាំ១៩៩២ ។ នៅប្រទេសជប៉ុន មានតែសាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូមួយប៉ុណ្ណោះដែលអាចរៀនមុខវិជ្ជាផ្សេងៗទាក់ទងនឹងខ្មែរ រយៈពេល៤ឆ្នាំ ដើម្បីទទួលបរិញ្ញាប័ត្រ។ រៀងរាល់ឆ្នាំសាកលវិទ្យាល័យ TUFS ធ្វើការប្រឡងជ្រើសរើសនិស្សិត ចូលរៀនផ្នែកភាសាខ្មែរចំនួន១០នាក់ពីទូទាំងប្រទេសជប៉ុន។ មកដល់បច្ចុប្បន្ននេះ និស្សិតដែលបានបញ្ចប់ការសិក្សាផ្នែកភាសាខ្មែរមានជាង ១២០នាក់ហើយ ហើយត្រូវបានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ស្ថាប័នអប់រំ ក្រុមហ៊ុនឯកជន សារមន្ទីរ ក្រសួងនានា ធនាគារ ស្ថានទូតជប៉ុន...។ល។ជ្រើសរើសឲ្យបម្រើការងារ។

## គ្រូផ្នែកភាសាខ្មែរ

សាស្ត្រាចារ្យដែលបង្រៀនភាសាខ្មែរមានចំនួន៣នាក់។ សាស្ត្រាចារ្យ២នាក់ ជាជនជាតិជប៉ុន និងសាស្ត្រាចារ្យ១នាក់ជាជនជាតិខ្មែរមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ក្រៅពីនេះនៅមានសាស្ត្រាចារ្យជាច្រើននាក់ទៀតដែលមកពីសាកលវិទ្យាល័យផ្សេងៗមកបង្រៀននៅសាកលវិទ្យាល័យរបស់យើងផងដែរ។

## កម្មវិធីសិក្សាសម្រាប់និស្សិតផ្នែកភាសាខ្មែរ

ក្នុងកម្មវិធីសម្រាប់និស្សិតភាសាខ្មែរ យើងចែកថ្នាក់រៀនភាសាខ្មែរទៅតាមប្រភេទនិងកម្រិត។ និស្សិតគ្រប់ឆ្នាំទាំងអស់ត្រូវរៀនរយៈពេល១ម៉ោង៣០នាទី ក្នុងមួយសប្តាហ៍ និងក្នុងមួយឆមាសបានទទួល ១ក្រេឌីត។ និស្សិតអាចបញ្ចប់ការសិក្សានៅសាកវិទ្យាល័យបាន លុះត្រាតែមានក្រេឌីតយ៉ាងតិច ២៨ក្រេឌីតនៃផ្នែកភាសាខ្មែរ ក្នុងចំណោម ១២៦ក្រេឌីត។

ផ្នែកភាសាខ្មែរមានកម្មវិធីផ្សេងៗជាច្រើនដូចជា ការរៀនអំពីរបៀបសំពះ ការលេងល្បែងប្រជាប្រិយ ការរាំវង់ រាំក្បាច់សារ៉ាវ៉ាន់ របៀបប្រើប្រាស់ក្រមាក្នុងជីវភាពប្រចាំថ្ងៃ របៀបចងក្បិន របៀបស្លៀកសំពត់និងការសម្តែងស្បែកធំនិងស្បែកតូច...ជាដើម ដើម្បីឲ្យនិស្សិតស្វែងយល់អំពីប្រទេសខ្មែរ។

## សារណាបរិញ្ញាប័ត្រផ្នែកភាសាខ្មែរ

ក្នុងឆ្នាំទី៤ និស្សិតដែលត្រូវបញ្ចប់ឆ្នាំសិក្សា ត្រូវសរសេរសារណារបស់ខ្លួនហើយប្រគល់សារណាជូនទៅសាស្ត្រាចារ្យដឹកនាំនៅខែមករា។ នៅដើមខែកុម្ភៈ និស្សិតទាំងនោះត្រូវឡើងការពារសារណារៀងៗខ្លួន។ ចាប់ពីឆ្នាំ ២០០០ ដល់ ២០០៩ នេះ មានចំនួនប្រធានបទលើសពី១០០ហើយដែលបានការពារ។ ចំណែកពិធីប្រកាសទទួលសញ្ញាប័ត្រប្រព្រឹត្តទៅនៅចុងខែមីនា ហើយនិស្សិត ដែលនឹងឡើងទទួលសញ្ញាប័ត្រនេះ ត្រូវស្លៀកពាក់តាមប្រពៃណីរបស់ប្រទេសកម្ពុជា និស្សិតស្រី ស្លៀកពាក់អាវប៉ាក់ ហូល ឬផាមួង និងកន្សែង៣នា ឯនិស្សិតប្រុស ស្លៀកឯកសណ្ឋានអាវធំ។




*ពិធីទទួលសញ្ញាប័ត្រ*



*ការលេងបោះអង្គញ់អបអរពិធីចូលឆ្នាំខ្មែរ*





*ការបង្ហាញពីរបៀបប្រើក្រមា*

# ■ ទំនាក់ទំនងជាមួយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ■

## កិច្ចព្រមព្រៀងផ្លាស់ប្តូរការសិក្សានិងសហប្រតិបត្តិការរវាងសាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូ(TUFS)និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP)

សាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូ និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្លាស់ប្តូរការសិក្សា និងសហប្រតិបត្តិការ រវាងសាកលវិទ្យាល័យទាំងពីរ បានពីរដងរួចមកហើយ។ ថ្មីៗនេះនៅថ្ងៃទី១៧ខែធ្នូឆ្នាំ២០០៩សាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូ និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្លាស់ប្តូរការ សិក្សានិងសហប្រតិបត្តិការរវាងសាកលវិទ្យាល័យទាំងពីរជាថ្មីម្តងទៀត ដែលមានរយៈពេល ៥ឆ្នាំ គិតចាប់ពីឆ្នាំ ២០១០តទៅ ហើយការចុះហត្ថលេខានេះ ប្រព្រឹត្តទៅ នៅព្រះរាជាណាចក្រកម្ពុជា នាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

លោក កាមេយ៉ាម៉ា សាកលវិទ្យាធិការ និងលោកស្រីសាស្ត្រាចារ្យភាសាខ្មែរពីរនាក់ ព្រមទាំងបុគ្គលិករដ្ឋបាលម្នាក់នៃសាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូ បានធ្វើដំណើរទៅកាន់ព្រះរាជាណាចក្រកម្ពុជា ដើម្បីជួបជាមួយនឹង ឯកឧត្តម ឡៅ ឈីវអ៊ារ សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងលោកសាស្ត្រាចារ្យ ហង់ចាន់ថុន ជាសាកលវិទ្យាធិការរង ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្លាស់ប្តូរការសិក្សា និងសហប្រតិបត្តិការ រវាងសាកលវិទ្យាល័យទាំងពីរ។ បន្ទាប់ពីនោះ លោក កាមេយ៉ាម៉ា ក៏បាន អញ្ជើញទៅមើលតូបលក់សៀវភៅ អាហារដ្ឋាននិស្សិត ទិដ្ឋភាពក្នុងសាកលវិទ្យាល័យផងដែរ។

សាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូ បានផ្តល់ឯកសារមួយចំនួនដល់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដូចជា វចនានុក្រមខ្មែរ-ជប៉ុន សៀវភៅកម្រងវាក្យសព្ទខ្មែរ-ស្អូច-ជប៉ុន សៀវភៅឯកសារស្រាវជ្រាវរបស់សាស្ត្រាចារ្យ នៅក្នុងសាកលវិទ្យាល័យ និងព្រឹត្តិប័ត្រពត៌មានប្រចាំឆ្នាំ របស់សាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូ។ ចំណែកសាកលវិទ្យាល័យភូមិន្ទភ្នំពេញក៏បានឲ្យសៀវភៅ Hand book មកសាកលវិទ្យាល័យយើងជារៀងរាល់ឆ្នាំដែរ។

## និស្សិតផ្លាស់ប្តូរមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ចាប់តាំងពីឆ្នាំ ២០០០ ដល់ ២០០៩ និស្សិតជប៉ុនដែលបានមករៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានចំនួន ១៥នាក់ហើយ។ ឯនិស្សិតខ្មែរដែលបានមករៀននៅសាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូមានចំនួន ៩នាក់។

និស្សិតខ្មែរត្រូវបានសាកលវិទ្យាល័យTUFS យកចិត្តទុកដាក់ទាំងការរស់នៅ ទាំងការសិក្សារបស់គេ។ និស្សិតត្រូវចុះឈ្មោះរៀនភាសាជប៉ុនតាមកម្រិតដែលគេបានធ្វើតេស្តមុនចូលរៀន និងជ្រើសរើសមុខវិជ្ជាផ្សេងៗទៀតជាភាសាអង់គ្លេស ដែលមានក្នុងកម្មវិធីសិក្សា។

និស្សិតខ្មែរមានឱកាសយ៉ាងច្រើនក្នុងការទាក់ទងជាមួយនិស្សិតជប៉ុនដែលរៀនភាសាខ្មែរ ជាពិសេសគេអាចអនុវត្តការនិយាយភាសាជប៉ុនរបស់ខ្លួនបានយ៉ាងល្អ។ ក្រៅពីពេលសិក្សា ពួកគេមានកម្មវិធីធ្វើដំណើរកម្សាន្តទៅកាន់រមនីយដ្ឋានផ្សេងៗជាច្រើនក្នុងទីក្រុងតូក្យូ ក្នុងនោះពួកគេក៏បានទៅហាងដែលមានលក់ម្ហូបខ្មែរ និងម្ហូបជប៉ុនផងដែរ។ លើសពីនេះ នៅពេលវិស្សមកាល ពួកគេតែងត្រូវបានមិត្តភក្តិជប៉ុន អញ្ជើញទៅស្នាក់នៅផ្ទះរបស់គេ នៅតាមខេត្តដែលនៅជិត ឬឆ្ងាយពីតូក្យូ ដើម្បីបង្កើនភាពស្និទ្ធស្នាល និងឲ្យនិស្សិតខ្មែរបានសិក្សាស្វែងយល់បន្ថែមទៀតពី វប្បធម៌ប្រពៃណី និងការរស់នៅរបស់ប្រជាជនជប៉ុន។



*ពិធីចុះកិច្ចព្រមព្រៀងរវាងសាកលវិទ្យាល័យទាំងពីរនៅភ្នំពេញ*



*អតីតឯកអគ្គរាជទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា លោក ស្ទីណូហារ៉ា និងសាកលវិទ្យាធិការ TUFS លោក កាមេយ៉ាម៉ា ជួបសំណេះសំណាលជាមួយនិស្សិតខ្មែរ និង និស្សិតជប៉ុនផ្នែកភាសាខ្មែរ*

# កម្មវិធីកម្សាន្ត

## ដំណើរកម្សាន្តសិក្សា

នៅដើម ខែមេសា ជាបវេសនកាលឆ្នាំសិក្សាថ្មី និស្សិតផ្នែកភាសាខ្មែរឆ្នាំទី១និងឆ្នាំទី២ បានធ្វើដំណើរទៅតាមខេត្តដែលនៅជិតៗតូក្យូដូចជា ណាហ្កាណូហើយស្នាក់នៅមួយយប់។ និស្សិតទាំងអស់ត្រូវបានណែនាំឲ្យយល់ដឹង ពីប្រទេសកម្ពុជា និងឆ្លើយសំណួរ ។ ដើម្បីឲ្យមានភាពងាយស្រួល ពួកគេត្រូវបានបែងចែកជាក្រុមពិភាក្សាពី ៥ក្រុម ទៅ ៦ក្រុម ហើយពិភាក្សាលើសំណួរ ដែលទាក់ទងនឹងវប្បធម៌, សិល្បៈ, ប្រពៃណី, ទំនៀមទម្លាប់ និងសៀវភៅបង្រៀនភាសាខ្មែរ។ និស្សិតនៅក្នុងក្រុមនិមួយៗ ឡើងពន្យល់បកស្រាយអំពីប្រធានបទរបស់ខ្លួនយ៉ាងក្បោះក្បាយហើយបន្ទាប់មក ក្រុមដទៃទៀត ចោទជាសំណួរមួយចំនួនដែលពាក់ព័ន្ធទៅនឹងប្រធានបទនោះ។ ចុងបញ្ចប់នៃការពិភាក្សាយើងធ្វើការបូកសរុបពិន្ទុ និងវាយតម្លៃថា តើក្រុមណាដែលបកស្រាយបានល្អជាងគេ ដូច្នេះក្រុមនោះ អាចមានឱកាសក្នុងការជ្រើសរើសរង្វាន់មុនគេ។

## ទិវាមហាវិទ្យាល័យ

រៀងរាល់ខែវិច្ឆិកា សាកលវិទ្យាល័យមានរៀបចំធ្វើទិវាមហាវិទ្យាល័យដែលជាពិធីបុណ្យមួយមានរយៈពេល១អាទិត្យ ក្នុងពិធីបុណ្យនេះ និស្សិតផ្នែកភាសាទាំងអស់បានរៀបចំធ្វើ ម្ហូបអាហារដាក់លក់ និងសម្តែងសិល្បៈជាភាសាផ្សេងៗជូនភ្ញៀវទស្សនា។ ទិវានេះឆ្លុះបញ្ចាំងឲ្យឃើញនូវសមិទ្ធិផលមួយដែលពួកគេបានសិក្សាកន្លងមកហើយក៏ជាឱកាសមួយដ៏ល្អឲ្យនិស្សិតទាំងអស់និងអាណាព្យាបាលរបស់គេព្រមទាំងជនជាតិជប៉ុននិងបរទេស បានដឹងពីវប្បធម៌នៃប្រទេសផ្សេងៗនៅលើពិភពលោកនេះ។ វាក៏ជាពេលវេលាមួយយ៉ាងសប្បាយរីករាយដែលនិស្សិតទាំងអស់រង់ចាំអស់ពេលជាយូរដើម្បីបង្ហាញនូវស្នាដៃរបស់ខ្លួន។

ចំពោះផ្នែកភាសាខ្មែរវិញនិស្សិតឆ្នាំទី២ សម្តែងល្ខោនបែបបុរាណ ឬសម័យទៅតាមចំណង់ចំណូលចិត្តរបស់គេ ហើយការសម្តែងត្រូវនិយាយជាភាសាខ្មែរ។ ដើម្បីទាក់ទាញអារម្មណ៍អ្នកទស្សនា ពួកគេមានរចនាបដាចម្រុះ ដោយអក្សរខ្មែរជប៉ុន និងរូបតុ្លកផ្សេងៗ ។

រឿងល្ខោនដែលពួកគេយកមកហាត់សម្តែងភាគច្រើនជារឿងដែលមាននៅក្នុងកម្មវិធីសិក្សាដូចជា រឿងគង់ហ៊ាន(សម្តែង៤ដង), កុលាបប៉ៃលិន, សូផាត, ធុញ្ញជ័យ(សម្តែង៣ដង), ចិញ្ចៀនបញ្ចាំចិត្ត(សម្តែង២ដង), ទុំទាវ, បិទភ្នែកហែកទ្រូង, សុរិយាល្ងាចថ្ងៃ និង ទឹកចិត្តម្តាយ។

ក្នុងការសម្តែងរឿងល្ខោននេះ និស្សិតខ្មែរ ដែលមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក៏ចូលរួមសម្តែងជាមួយនឹងនិស្សិតរបស់យើងផងដែរ។

តំណាងស្ថានទូតខ្មែរប្រចាំនៅប្រទេសជប៉ុន ក៏បានអញ្ជើញមកចូលរួមទស្សនាល្ខោន ជាការលើកទឹកចិត្តដល់ និស្សិតផ្នែកភាសាខ្មែរនៅសាកវិទ្យាល័យយើងដែរ។

ចំណែកឯនិស្សិតឆ្នាំទី១ មុនពេលធ្វើបុណ្យនេះ គេបានរៀនធ្វើម្ហូបខ្មែរជាច្រើន ហើយមុខម្ហូបដែលពួកគេធ្វើសម្រាប់ថ្ងៃបុណ្យសាលានោះមានដូចជា បបរមាន់, គុយទាវឆា, បាញ់ឆែវ, សម្លការី, នំប៉ុងចៀន និងសង់ខ្យាល្ពៅ ជាដើម។ ក្នុងទិវាបុណ្យមហាវិទ្យាល័យមានភ្ញៀវជាច្រើនមកពីគ្រប់ទិសទីចូលរួម និងទិញម្ហូប ដែលយើងធ្វើ ពិសេសសង់ខ្យាល្ពៅជាបង្អែមមួយដែលភ្ញៀវជប៉ុននិយមចូលចិត្តច្រើនជាងគេ។

## ការប្រកួតកីឡាអុំទូក

នៅរៀងរាល់ឆ្នាំ ក្នុងខែឧសភា និស្សិតឆ្នាំទី១ដែលជាសមាជិកក្រុមកីឡាអុំទូកបានចេញប្រកួតការអុំទូកដែលចាត់ចែងដោយសាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូ។

និស្សិតទាំងប្រុស ទាំងស្រីខំប្រឹងអុំទូក ដើម្បីបញ្ចេញថ្វីដៃរបស់គេដែរ ហើយកន្លងមកនៅឆ្នាំ២០០៦ និស្សិតស្រីរបស់យើងបានឈ្នះការប្រកួត និងទទួលជ័យលាភីលេខ៣ នេះជាមោទនភាពមួយរបស់យើងនិង TUFS ផងដែរ។





*ការសម្តែងក្នុងរឿង "សុរិយាល្ងាចថ្ងៃ"*



*ការសម្តែងក្នុងរឿង "ទឹកចិត្តម្តាយ"*

# ■ ការងារប្រចាំថ្ងៃរបស់និស្សិតជប៉ុន ■

ក្នុងអត្ថបទនេះយើងលើកយកការងារប្រចាំថ្ងៃរបស់និស្សិតជប៉ុនម្នាក់មកអធិប្បាយ។ ក្នុងគោលបំណងចែករំលែកពីជីវិតរស់នៅរបស់និស្សិតជប៉ុនឲ្យខ្មែរបានយល់ដឹងកាន់តែច្បាស់ថា និស្សិតភាគច្រើននៅជប៉ុនរៀនបណ្តើរធ្វើការបណ្តើរជារឿងធម្មតា។ តទៅនេះយើងសូមលើកយកការងារប្រចាំថ្ងៃរបស់ និស្សិតជប៉ុនម្នាក់ឈ្មោះ រ្យូកុ ជានិស្សិតឆ្នាំទីបីផ្នែកភាសាខ្មែរហើយនាងមកពីខេត្តហុកកៃដូ។ ឥឡូវនេះនាងរស់នៅតែម្នាក់ឯងនៅជិតសាលា។តើជីវិតរស់នៅប្រចាំថ្ងៃរបស់នាងយ៉ាងម៉េចដែរ ?

## ថ្នាក់រៀនភាសាខ្មែរ

ក្នុងមួយអាទិត្យ នាងមានថ្នាក់រៀនភាសាខ្មែរ៣ម៉ោង ក្នុងនោះមាន ការបកប្រែរបាយការណ៍របស់អង្គការ NGO និងសៀវភៅផ្សេងៗ, សរសេរពីពត៌មានក្នុងនិងក្រៅប្រទេស និងចងក្រងឯកសារទាក់ទងនឹងបញ្ហាខ្មែរ ។ នាងខំប្រឹងបកប្រែនិងសរសេរជាមួយពួកម៉ាក ក្រោមការដឹកនាំរបស់អ្នកគ្រូ។ ហើយ ដោយសារការខិតខំប្រឹងប្រែងរបស់នាង នាងទទួលបានការកោតសរសើរពីមិត្តភក្តិ ព្រមទាំងអ្នកគ្រូទាំងអស់ផងដែរ ។

## ថ្នាក់រៀនក្រៅភាសាខ្មែរ

ក្រៅពីរៀនភាសាខ្មែរ នាងរៀនមុខវិជ្ជាផ្សេងទៀតជាភាសាអង់គ្លេសគឺ អំពីបញ្ហាបរិស្ថាន ។ មុខវិជ្ជានេះមានសារៈសំខាន់ចំពោះនាងណាស់ ពីព្រោះនាងមានចំណាប់អារម្មណ៍សរសេរសារណាពេលបញ្ចប់ឆ្នាំសិក្សាអំពីបញ្ហាបរិស្ថាននៅប្រទេសកម្ពុជា។

## អាហារថ្ងៃត្រង់

រ្យូកុទៅញ៉ាំអាហារពេលថ្ងៃនៅភោជនីយដ្ឋានក្នុងសាលាជាមួយពួកម៉ាករបស់នាង។ពេលនោះនិស្សិតដែលរៀនមុខវិជ្ជាផ្សេងៗទៀតក៏បានមកភោជនីយដ្ឋានដែរ។នាងចូលចិត្តញ៉ាំម្ហូបជប៉ុន ជាពិសេសគឺអ៊ូដុង ព្រោះអ៊ូដុងមានរសជាតិឆ្ងាញ់ហើយមានតម្លៃសមរម្យ។ ភោជនីយដ្ឋាននេះមិនត្រឹមតែមានម្ហូបជប៉ុនប៉ុណ្ណោះទេពេលខ្លះក៏មានម្ហូបបរទេសដែរដូចជាម្ហូបកូរ៉េ វៀតណាម ថៃ ជាដើម។បន្ទាប់ពីនាងញ៉ាំអាហារថ្ងៃត្រង់រួចនាងបានជជែកលេងជាមួយនិស្សិតទាំងនោះ។ ប៉ុន្តែពេលខ្លះ នាងបានយកបាយទៅញ៉ាំនៅបន្ទប់ការិយាល័យរបស់អ្នកគ្រូ ដើម្បីបានជជែកលេងជាមួយពួកគាត់ ពិសេសអ្នកគ្រូដែលមកពីខ្មែរ ហើយទីនោះក៏មាននិស្សិតខ្មែរ និងនិស្សិតជប៉ុនមកញ៉ាំដែរ។ អំឡុងពេលរង់ចាំថ្នាក់រៀនបន្តពេលខ្លះនាងអត់មានថ្នាក់រៀនទេ ដូច្នេះនាងត្រូវទៅបណ្ណាល័យ ដើម្បីអានសៀវភៅនិងធ្វើកិច្ចការភាសាខ្មែរ។ ក្នុងបណ្ណាល័យនេះនិស្សិតអាចប្រើកុំព្យូទ័រផ្ទាល់ខ្លួន អាចខ្ចីសៀវភៅហើយក៏អាចអានកាសែត ទស្សនាវដ្តីបានដែរ។ ពេលជិតប្រឡងនិស្សិតជាច្រើនបានមកបណ្ណាល័យនេះ។ បន្ទាប់ពីនាងធ្វើកិច្ចការភាសាខ្មែររួច នាងបានមើលព័ត៌មានទាក់ទងនឹងប្រទេសខ្មែរតាមវេបសាយ។ នៅពេលរសៀល នាងតែងទៅទីធ្លាក្នុងសាលាដើម្បីលេងតេន្នីសជាមួយសមាជិកក្រុមកីឡា។ កីឡាតេន្នីសនេះមានប្រជាប្រិយភាពណាស់សម្រាប់និស្សិតទូទៅ មិនថានិស្សិតប្រុស ឬស្រីទេ។ នាងលេងតេន្នីសរហូតដល់ម៉ោង៤និង២០នាទីល្ងាច។

## ការងារក្រៅម៉ោង

នាងរ្យូកុ ធ្វើការជាអ្នកបម្រើម្នាក់នៅក្នុងភោជនីយដ្ឋានមួយដើម្បីសន្សំលុយសម្រាប់រៀនក្រៅប្រទេសនិងត្រូវការលុយសម្រាប់ចាយវាយដូចជាទិញសម្លៀកបំពាក់ល្អៗ និងគ្រឿងតុបតែងខ្លួន ដើរលេង និងការកម្សាន្តតាមទីកន្លែងផ្សេងៗ។ នាងត្រូវធ្វើការទីនោះ បីដងក្នុងមួយអាទិត្យ។

មូលហេតុដែលនាងចូលចិត្តទៅធ្វើការពីព្រោះភោជនីយដ្ឋាននោះបានផ្តល់អាហារយ៉ាងឆ្ងាញ់ៗសម្រាប់នាង។ ពេលបានម្ចាស់ហាងផ្តល់អាហារសម្រាប់នាងបែបនេះ ធ្វើឲ្យនាងអាចសន្សំលុយបានមួយចំណែកទៀត។

## ចុងសប្តាហ៍

ទោះបីនាងរ្យូកុ រៀនផង ធ្វើការងារក្រៅម៉ោងផងក្តី ក៏នាងនៅ មានពេលវេលាខ្លះសម្រាប់លម្ហែផងដែរ។ នៅចុងសប្តាហ៍ ពេលខ្លះនាងបានទៅដើរលេងជាមួយមិត្តភក្តិ ដូចជាទៅញ៉ាំបាយល្ងាចជាមួយគ្នា ទៅផ្សារទិញសម្លៀកបំពាក់ និងគ្រឿងសម្អាង និងទៅកន្លែងកម្សាន្តនានាជាដើម។



*ការចូលរួមញ៉ាំអាហារពេលល្ងាចនៅផ្ទះមិត្តភក្តិ និងនៅក្នុងសាលា*

# ការសិក្សារបស់និស្សិតខ្មែរនៅប្រទេសជប៉ុន

## **ជីវិតរស់នៅស្រុកជប៉ុន** ដោយៈ ក. អេប ស្រីនាង

នាងខ្ញុំជានិស្សិតអក្សរសាស្ត្រខ្មែរនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ(RUPP)។ នេះជាលើកទីមួយ ដែលនាងខ្ញុំបានចាកចេញពីប្រទេសកំណើតរបស់ខ្លួនមកបរទេសដូចនេះ ហើយជាឱកាសមួយដ៏ល្អសម្រាប់ខ្ញុំក្នុងការរស់នៅដោយខ្លួនឯងមិននៅជិតឪពុកម្តាយនិងធ្វើឲ្យខ្លួនឯងមានទំនួលខុសត្រូវ។

ដល់ប្រទេសជប៉ុនភ្លាម នាងខ្ញុំឃើញថា ប្រទេសជប៉ុនមានភាពខុសគ្នានឹងប្រទេសខ្មែរច្រើន។ ភាគច្រើននៃការបម្រើសេវាកម្មសុទ្ធតែជាគ្រឿងម៉ាស៊ីន មានជាក់ស្តែងដូចជា ការទិញសំបុត្ររទេះភ្លើង ការទិញភេសជ្ជៈ ជាដើម។ នាងខ្ញុំស្នាក់នៅបន្ទប់អន្តេវាសិកដ្ឋានក្នុងបរិវេណសាកលវិទ្យាល័យ។ បន្ទប់នោះមានការរៀបចំស្អាត ហើយទោះបីជាវាតូចបន្តិចមែន ខ្ញុំគិតថាសមល្មមនឹងរស់នៅម្នាក់ឯង ជាអគារស្ងាត់និងមានសន្តិសុខល្អប៉ុន្តែនៅពេលព្រឹកមានសំឡេងអ៊ូអរបន្តិចដោយសារនៅជិតនោះមានកន្លែងហាត់កីឡាមួយដែលនិស្សិតណាក៏អាចចូលលេងបានដែរ។

ម៉ោងសិក្សាភាសាជប៉ុនចាប់ផ្តើមពីម៉ោងប្រាំបួនដល់ម៉ោងដប់ពីរនិងដប់នាទី។ នៅក្នុងថ្នាក់ ខ្ញុំបានជួបនិស្សិតបរទេសដែលមកពីប្រទេសនៅអាស៊ីនិងអឺរ៉ុប។ ក្រៅពីថ្នាក់ភាសាជប៉ុន និស្សិតអាចជ្រើសរើសថ្នាក់ផ្សេងទៀតដែលបង្ហាត់ជាភាសាអង់គ្លេស ។ ជាការប្រសើរណាស់ដែលសាលាមានកម្មវិធីសិក្សាបែបនេះ ព្រោះអាចធ្វើឲ្យនិស្សិតមានការរីកចម្រើនយ៉ាងឆាប់រហ័ស។ នៅក្នុងថ្នាក់ ពួកយើងត្រូវធ្វើការងារជាក្រុម ដូចនេះវាជាឱកាសមួយដែលធ្វើឲ្យយើងបានស្គាល់គ្នា។

នៅពេលមកដល់ជប៉ុនថ្ងៃដំបូង នាងខ្ញុំ បានញ៉ាំស៊ូស៊ី ដែលជាម្ហូបល្បីនៅស្រុកជប៉ុន។ ពេលនោះខ្ញុំមិនអាចញ៉ាំបានទេ ព្រោះខ្ញុំមិនធ្លាប់ញ៉ាំត្រីឆៅ ដូចនេះវាពិបាកបន្តិចសម្រាប់ខ្ញុំ ។ នៅពេលដែលខ្ញុំបានទៅកន្លែងណាមួយ ខ្ញុំតែងសាកល្បងញ៉ាំម្ហូបប្លែកៗដូចជា ឧដុង តិមពុរា សារ៉ាដាក់ យ៉ាគីនីគុ ជាដើម ។

ទន្ទឹមនឹងស្វែងយល់អំពីប្រទេសជប៉ុន យើងទាំងអស់គ្នាក៏បានស្វែងយល់ពីគ្នាទៅវិញទៅមកដែរ ។ដូចជាការធ្វើម្ហូបនៃប្រទេសរៀងៗខ្លួនរួចញ៉ាំជុំគ្នា និងជជែកគ្នាលេង។



*ការស្លៀកពាក់បែបប្រពៃណីជប៉ុន*

## **សំណាក់តាមផ្ទះ (Homestay)** ដោយៈ ក. សៀ លីដា

ពិតប្រាកដណាស់!សម្រាប់និស្សិតបរទេសដែលកំពុងសិក្សានៅប្រទេសជប៉ុនចាំបាច់ត្រូវរៀនភាសាជប៉ុន ដើម្បីជាជំនួយក្នុងការសិក្សានិងការប្រាស្រ័យទាក់ទងក្នុងការរស់នៅរបស់ខ្លួន។ សំណាក់តាមផ្ទះ គឺការស្នាក់នៅមួយរយៈជាមួយគ្រួសារជប៉ុន។

ជាឧទាហរណ៍៖ នៅវិស្សមកាលរដូវរងា ឆ្នាំ២០០៩ ខ្ញុំបានទៅ Homestay នៅឯខេត្តហ្វិគូអូកា ដែលស្ថិតនៅតំបន់គ្យូស្យូ។ នៅទីនោះខ្ញុំបានចូលរួមធ្វើនំម៉ូឈិ ដែលជានំប្រពៃណីរបស់ជប៉ុនសម្រាប់ពិធីបុណ្យចូលឆ្នាំជាមួយក្រុមគ្រួសារជនជាតិជប៉ុនដែលខ្ញុំបានស្នាក់នៅជាមួយ។នៅពេលនោះហើយដែលខ្ញុំទើបតែដឹងថា នំម៉ូឈិ មានរាងខុសគ្នារវាងតំបន់ភាគខាងត្បូង និងខាងជើងនៃប្រទេសជប៉ុន។ ពោលគឺថានំម៉ូឈិនៅតំបន់ភាគខាងត្បូងមានរាងមូល រីឯនំម៉ូឈិ នៅតំបន់ភាគខាងជើងវិញ មានរាងបួនជ្រុង។

### មិត្តភាពនិងការទំនាក់ទំនង:

តាមរយៈ Homestay យើងបានស្គាល់នូវមនុស្សថ្មីៗជាច្រើននៅជុំវិញខ្លួនរបស់យើង ជាពិសេសគឺក្រុមគ្រួសារដែលបានទទួលយើងឲ្យស្នាក់នៅជាមួយ គឺពួកគាត់បានចាត់ទុកយើងដូចជាកូន ជាសមាជិកម្នាក់នៅក្នុងគ្រួសាររបស់គាត់ដែរ។ ទឹកចិត្តនិងក្តីស្រឡាញ់របស់គាត់បានធ្វើឲ្យយើងមានភាពកក់ក្តៅដូចជាក្រុមគ្រួសារទីពីររបស់យើងដែរ។ ទោះបីជារយៈពេល Homestay បានបញ្ចប់ទៅហើយក្តី ក៏យើងនៅតែទំនាក់ទំនងគ្នាតាមរយៈទូរស័ព្ទ សំបុត្រ ជាដើម។

### ការរីកចម្រើននូវសមត្ថភាពភាសាជប៉ុន:

Homestayគឺជាឱកាសមួយដ៏ល្អសម្រាប់អនុវត្តភាសាជប៉ុន។ ជួនកាលក្រុមគ្រួសារដែលយើងស្នាក់នៅជាមួយពួកគាត់ចេះនិយាយតែភាសាជប៉ុនប៉ុណ្ណោះ។ នៅពេលនោះហើយដែលយើងអាចធ្វើការកត់សម្គាល់បានថាសមត្ថភាពភាសាជប៉ុនរបស់យើងអាចមានភាពរីកចម្រើនជាងមុនជាពិសេសគឺចំណេះដឹងផ្នែកវាក្យសព្ទប្រើប្រាស់ប្រចាំថ្ងៃ។ជាក់ស្តែងនៅពេលដែលខ្ញុំទើបតែមកដល់ប្រទេសជប៉ុនដំបូងហើយមិនទាន់មានចំណេះដឹងផ្នែកភាសាជប៉ុន សូម្បីតែបន្តិចនោះ ខ្ញុំបានទៅខេត្តស៊ីហ្សូអូកាជាលើកដំបូង។នៅពេលនោះ ជារៀងរាល់ថ្ងៃយើងបានប្រើវចនានុក្រមអេឡិចត្រូនិចបណ្តើរជជែកគ្នាលេងបណ្តើរឬក៏ប្រើកាយវិការក្នុងការប្រាស្រ័យទាក់ទងគ្នាយ៉ាងសប្បាយរីករាយ។

### ការណែនាំបង្ហាញអំពីវប្បធម៌ខ្មែរ:

Homestay ជាឱកាសមួយដែលអាចឲ្យយើងណែនាំបង្ហាញ

ពីប្រពៃណីវប្បធម៌របស់ខ្មែរយើងដល់ពួកគាត់ផងដែរ។ រៀងរាល់ពេលដែលខ្ញុំទៅ Homestay ខ្ញុំមិនភ្លេចនាំទៅជាមួយនូវរូបភាពនានាអំពីប្រទេសខ្មែរដើម្បីបង្ហាញពួកគាត់ ហើយជាពិសេសជាងនេះទៅទៀតនោះ ខ្ញុំតែងតែធ្វើ ម្ហូបខ្មែរជូនពួកគាត់ផងដែរ។ ទោះបីជារសជាតិនោះឆ្ងាញ់ឬមិនឆ្ងាញ់ក៏ដោយ ពួកគាត់បានបង្ហាញនូវភាពរីករាយជាខ្លាំងដោយសារតែពួកគាត់បានភ្លក់ម្ហូបខ្មែរជាលើកដំបូងក្នុងជីវិតរបស់គាត់។



*ការទទួលទានអាហារពេលល្ងាចមុនពេលឆ្លងចូលឆ្នាំថ្មី (Homestay នាវិស្សមកាលរដូវរងាឆ្នាំ២០០៩នៅខេត្តហ្វ៊ុគូអូកា)*

## អត្តចរិកមួយចំនួនរបស់ជប៉ុនដែលគួរយកគំរូតាម

ដោយ: ហាក់ សិរី

រយៈពេលជិតមួយឆ្នាំបានកន្លងផុតទៅហើយ បន្ទាប់ពីខ្ញុំបានឈានជើងចូលក្នុងទឹកដីប្រទេសជប៉ុន។ក្នុងរយៈពេលនេះ ខ្ញុំបាទសង្កេតឃើញ អត្តចរិក និង សកម្មភាពមួយចំនួនរបស់ជនជាតិជប៉ុន ដែលគួរ យកមកអនុវត្តតាម ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន និង សង្គមជាតិ ទាំងមូលផងដែរ។

**១. ការគោរពច្បាប់ និង សុជីវធម៌ក្នុងទីសាធារណៈ**

ពេលទើបមកដល់ដំបូង ខ្ញុំបាទសង្កេតឃើញថាជនជាតិជប៉ុនពិតជាគោរពច្បាប់ទម្លាប់បានល្អមែន តួយ៉ាងដូចជាច្បាប់ចរាចរជាដើម។ ប្រសិនបើភ្លើងសញ្ញាចរាចរប្តូរទៅជាពណ៌ក្រហមហើយនោះ ទោះជាពេលយប់ស្ងាត់ ហើយគេច្បាស់ក្នុងចិត្តថាគ្មានយានយន្តមកពីទិសផ្សេងទៀតក៏ដោយ ក៏អ្នកបើកបររថយន្ត នឹងមិនបន្តដំណើរទៅមុខទេ។

មួយផ្សេងទៀត គឺការរក្សាអនាម័យបរិស្ថានជុំវិញខ្លួន។ ខ្ញុំកម្របានឃើញទិដ្ឋភាពជនជាតិ ជប៉ុនបោះចោលសំរាមតាមទីសាធារណៈណាស់។

ទិដ្ឋភាពដ៏ល្អមួយទៀតនោះ គឺការឈរតម្រង់ជួរ។ តាមទីកន្លែងចង្អៀតនានា គេឃើញមានតែការតម្រង់ជួរដ៏វែង។ ការធ្វើបែបនេះ មិនត្រឹមតែបង្ហាញពីសីលធម៌សង្គមមួយដ៏ល្អ និងសណ្តាប់ធ្នាប់សង្គមប៉ុណ្ណោះទេ គឺវាថែមទាំងបង្កើតឲ្យមានភាពយុត្តិធម៌ក្នុងសង្គមទៀតផង។ លើសពីនេះទៅទៀតនោះ ដំណើរទៅមុខគឺមានល្បឿនលឿន ហើយការរង់ចាំក៏មិនមានរយៈពេលយូរដែរ។

ការសុំទោស និង ការថ្លែងអំណរគុណជារឿយៗ គឺជាអត្តចរិកដ៏ល្អមួយរបស់ជនជាតិជប៉ុន។ ជាការពិតណាស់ខ្មែរជាជនជាតិមួយដែលប្រកាន់ខ្ជាប់នូវសីលធម៌រស់នៅក្នុងសង្គម។ ក៏ប៉ុន្តែ ខ្ញុំសង្កេតឃើញថា ចំនួនដងក្នុងការប្រើពាក្យសុំទោស និង អរគុណ របស់ក្មេងយុវវ័យខ្មែរបច្ចុប្បន្ន នៅមានចំនួនតិចនៅឡើយបើប្រៀបធៀបជាមួយជនជាតិជប៉ុន។ បញ្ហាជាច្រើនហួសពីការស្មាន ក៏អាចនឹងជៀសផុតបាន ប្រសិនបើយើងត្រេកអរ នឹងពាក្យថា អរគុណ និងប្រសិនបើយើងអធ្យាស្រ័យ នៅពេលឮពាក្យថា សុំទោស។

**២. សេវាកម្មដ៏ល្អ**

នៅតាមហាងទំនិញតូចធំគ្រប់ទីកន្លែង គឺមានភាពអ៊ូអរមានភ្ញៀវចេញចូលឥតអាក់។ បើក្រឡេកទៅមើល អ្នកលក់ក្នុងហាងវិញនោះ គឺឃើញតែស្នាមញញឹមរួសរាយរាក់ទាក់ និង សម្តី ស្រទន់ សុភាពរាបសារ មកកាន់អតិថិជន មិនថាជាជនជាតិជប៉ុន ឬ ជនបរទេសនោះទេ។ ការទទួលស្វាគមន៍ដ៏កក់ក្តៅនេះ ធ្វើឲ្យភាគីអតិថិជនមានអារម្មណ៍ល្អនឹងទទួលទិញទំនិញ និង សេវាកម្មផ្សេងៗ ហើយហាងទំនិញផ្ទាល់ក៏ដំណើរការទៅមុខយ៉ាងរលូនដែរ។

**៣. ពេលវេលាជាមាសប្រាក់ ត្រូវតែខំប្រឹង**

ពេលវេលាជារបស់សំខាន់ណាស់ សម្រាប់ជនជាតិជប៉ុន។ តែមួយនាទីប៉ុណ្ណោះ អាចឲ្យខកការណាត់ជួបដ៏សំខាន់ណាមួយក្នុងមុខជំនួញ ដូចជាករណីមកមិនទាន់ម៉ោងរថភ្លើងជាដើម។ ដោយមានសំពាធពីសេដ្ឋកិច្ច និង បរិយាកាសសង្គម អ្នករាល់គ្នាត្រូវតែខំប្រឹង។ តួយ៉ាងដូចជានិស្សិតមហាវិទ្យាល័យ ត្រូវខិតខំធ្វើការក្រៅម៉ោងសិក្សា អ្នកធ្វើការក្រុមហ៊ុនខិតខំបញ្ចប់ការងារ បើទោះជាហួសម៉ោងកាតព្វកិច្ចរបស់ខ្លួនក៏ដោយ ក្មេងៗមធ្យមសិក្សាខិតខំហ្វឹកហាត់កីឡារបស់ខ្លួនទាំងថ្ងៃឈប់សម្រាក។

ខ្ញុំគិតថាជប៉ុន និង ខ្មែរពិតជាមានលក្ខណៈ និង អត្តចរិកប្រហាក់ប្រហែលគ្នា។ ក៏ប៉ុន្តែ ឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃក្នុងស្រុករយៈពេលយូរ ធ្វើឲ្យខ្មែរបាត់បង់ភាពដើមល្អៗរបស់ខ្លួនមួយចំនួន។ ប៉ុន្តែខ្ញុំនៅតែមានការជឿជាក់ថា អត្តចរិកដ៏ល្អរបស់ខ្មែរ នឹងវិលមករកខ្មែរគ្រប់រូបវិញ ហើយខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំថា ខ្មែរនឹងរីកដុះដាលដូចកាលពីបុរាណសម័យជាក់ជាមិនខាន។



*ការដើរកម្សាន្តនៅឌីស្ស៊ីនីឡែន*

# ■ ទីតាំងសាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូ ■

១ អគារសិក្សា
២ អគារកីឡា
៣ អន្តេវាសិកដ្ឋាន
៤ មជ្ឈមណ្ឌលសុខភាព
៥ មជ្ឈមណ្ឌលភាសាជប៉ុនសម្រាប់និស្សិតបរទេស
៦ អគារផ្នែករដ្ឋបាល
៧ អគារនិស្សិត
៨ បណ្ណាល័យ
៩ អគារស្រាវជ្រាវភាសាវប្បធម៌ របស់អាស៊ីនិងអាហ្វ្រិក
១០ មហោស្រព







រៀបរៀងនិងចងក្រងដោយក្រុមនិស្សិតឆ្នាំទី៤ផ្នែកភាសាខ្មែរ
ដឹកនាំដោយសាស្ត្រាចារ្យ វ៉ា សោភា

រក្សាសិទ្ធដោយសាកលវិទ្យាល័យសិក្សាស្រាវជ្រាវបរទេសតូក្យូ
Tokyo University of Foreign Studies (TUFS)
Address: 3-11-1, Asahi-cho, Fuchu-shi, Tokyo, 183-8534, JAPAN
URL: http://www.tufs.ac.jp/
បោះពុម្ពលើកទី១នៅតូក្យូ (២០១០)